**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : .................✓.................

ថ្ងៃ សុក្រ ១២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០២៣

# ញត្តិគាំទ្រ
## ចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ
## លើសំណុំរឿងក្បត់ជាតិប្រព្រឹត្តដោយបុគ្គល កឹម សុខា

តាងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ យើងខ្ញុំសូមសម្តែងការគាំទ្រយ៉ាងពេញទំហឹងចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញដែលបានផ្តន្ទាទោសបុគ្គល កឹម សុខា ពីបទសន្ទិដ្ឋិភាពជាមួយបរទេស ឬបទឃុបឃិតគ្រូវ៉ូវគ្នាជាមួយបរទេស ដែលជាប្រភេទបទល្មើសក្បត់ជាតិ ដាក់ពន្ធនាគារកំណត់រយៈពេល ២៧ឆ្នាំ តាមមាត្រា៤៣៩ និងមាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងដកជាស្ថាពរនូវសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត និងសិទ្ធិធ្វើសកម្មភាពនយោបាយផ្សេងទៀត តាមមាត្រា៤៥០ នៃក្រមព្រហ្មទណ្ឌ ហើយក៏បានដាក់ជនជាប់ចោទឱ្យស្ថិតក្រោមវិធានការត្រួតពិនិត្យតាមផ្លូវការ មិនត្រូវចាកចេញពីបរិវេណនៃលំនៅឋាន មិនត្រូវឱ្យជួបបុគ្គលណាម្នាក់ ទាំងសញ្ជាតិខ្មែរ និងបរទេស លើកលែងតែក្រុមគ្រួសារ។ អំពើឃុបឃិតគ្រូវ៉ូវគ្នាជាមួយបរទេស ក្នុងការរៀបចំនិងអនុវត្តផែនការសម្ងាត់ ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា តាមទម្រង់នៃបដិវត្តពណ៌ គឺជាអំពើគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរបំផុតប៉ះពាល់ដល់ឯករាជ្យជាតិ សន្តិសុខជាតិ ស្ថិរភាពសង្គម និងភាពសុខសាន្តរបស់ប្រជាជនកម្ពុជាទាំងមូល និងជាពិសេសសន្តិភាពដែលរកបានដោយលំបាកតាមរយៈការបូជាអាយុជីវិតសាច់ស្រស់-ឈាមស្រស់ នៃយុទ្ធជន និងយុទ្ធនារីខ្មែរ។

សាលក្រមខាងលើនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការធានាថែរក្សាសុខសន្តិភាព និងភាពសុខសាន្តរបស់ប្រជាជនកម្ពុជា ហើយក៏ជាមេរៀនប្រៀនប្រដៅដល់អ្នកនយោបាយកម្ពុជាដទៃទៀត ឱ្យមានឧត្តមគតិស្រឡាញ់ជាតិ ស្មោះត្រង់នឹងជាតិ និងមិនក្បត់ប្រជាជនរបស់ខ្លួន ព្រមទាំងមិនត្រូវបណ្តោតបណ្តោយខ្លួនឱ្យក្លាយជាភ្នាក់ងារបម្រើឱ្យបរទេស ដើម្បីមហិច្ឆិតាអំណាចផ្ទាល់ខ្លួននោះទេ។

ជាថ្មីម្តងទៀត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញលើសំណុំរឿងក្បត់ជាតិប្រព្រឹត្តដោយបុគ្គល កឹម សុខា និងសូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប បន្តចូលរួមការពារស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងជាពិសេសគឺការពារសន្តិភាព បើទោះបីជាត្រូវលះបង់ដោយតម្លៃណាក៏ដោយ។